BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិក្នុងការចុះបញ្ជីកំណើតដែលមានធាតុបរទេសនៅវៀតណាម

CỘNG HÒA XÃ HỘI CHỦ NGHĨA VIỆT NAM
Độc lập - Tự do - Hạnh phúc

TỜ KHAI ĐĂNG KÝ KHAI SINH

Kính gửi: (1) .....

Họ, chữ đệm, tên người yêu cầu: .....
Ngày, tháng, năm sinh: .....
Nơi cư trú: (2) .....
.....
Giấy tờ tùy thân: (3) .....
.....
Quan hệ với người được khai sinh: .....
Đề nghị cơ quan đăng ký khai sinh cho người dưới đây:
Họ, chữ đệm, tên: .....
Ngày, tháng, năm sinh: ..... ghi bằng chữ: .....
.....
Giới tính: ..... Dân tộc: ..... Quốc tịch: .....
Nơi sinh: (4) .....
.....
Quê quán: .....
Họ, chữ đệm, tên người mẹ: .....
Năm sinh: (5) ..... Dân tộc: (2) ..... Quốc tịch: (2) .....
Nơi cư trú: (2) .....

ឆ្នាំ ២០២៥.

តើជំនួយគតិយុត្តិជាអ្វី?

ជំនួយគតិយុត្តិ គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្រប តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ។

អ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ រួមមាន៖

- អ្នកមានគុណបំណាច់ចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមលំបាកជាពិសេស។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ៖ គឺជាអ្នកត្រូវបានចោទប្រកាន់ អ្នកត្រូវបានស្នើសុំឲ្យចោទប្រកាន់ អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកជាប់ចោទ ជនរងគ្រោះ សាក្សី អ្នកអនុវត្តវិធានការដោះស្រាយបែបបង្វែរទិស និងទណ្ឌិត (អនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៦)។
- អ្នកចុងចោទដែលស្ថិតក្នុងគ្រួសារបៀតក្រីក្រ។
- ជនរងគ្រោះ អ្នកកំពុងស្ថិតក្នុងដំណើរការបញ្ជាក់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកអាយុក្រោម ១៨ ឆ្នាំដែលទៅជាមួយ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីណាមួយដូចខាងក្រោម ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ៖
- ឪពុកបង្កើត ម្តាយបង្កើត ភរិយា ស្វាមី កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ចិញ្ចឹមបីបាច់យុទ្ធជនពលីកាលនៅតូច។
- អ្នកឆ្លងជាតិពុលពណ៌ទឹកក្រូច (ដាយអុកស៊ីន)។
- មនុស្សចាស់។
- ជនពិការ។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលជាជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ។
- ជនរងគ្រោះក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារ។
- អ្នកផ្ទុកមេរោគអេដស៍ (HIV)។



- ពាក្យស្នើសុំជំនួយគតិយុត្តិ។
- លិខិតស្នាមបញ្ជាក់ថាជាអ្នកទទួលបានជំនួយគតិយុត្តិ។
- លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តី។

អាសយដ្ឋានទំនាក់ទំនងដើម្បីស្នើសុំជំនួយគតិយុត្តិ៖

- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុង ក្រោមឱវាទថ្នាក់កណ្តាល។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលចូលរួមជំនួយគតិយុត្តិ។
- អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅ៖
- គេហទំព័រនីតិកម្មជាតិ *(https://phapluat.gov.vn/)*
- គេហទំព័រព័ត៌មានអេឡិចត្រូនិកក្រសួងយុត្តិធម៌ *(https://dstrogiupphaply.moj.gov.vn/all/searchOrganization)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកជំនួយគតិយុត្តិវៀតណាម *(https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកមន្ទីរយុត្តិធម៌។
- លោកអ្នកអាចទាក់ទងតាមបណ្តាញដូចខាងក្រោម ដើម្បីដឹងព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖
- ខ្សែទូរស័ព្ទទាន់ហេតុការណ៍អំពីជំនួយគតិយុត្តិ៖ *18001233/02462739631*
- ទាញយកកម្មវិធីទូរស័ព្ទចល័តអំពីជំនួយគតិយុត្តិ។

លិខិតស្នាមដែលត្រូវបង្ហាញ៖

ផ្អែកលើមាត្រា ៧ មាត្រា ១៣ មាត្រា ១៤ មាត្រា ៣៥ មាត្រា ៣៦ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋានរបស់រដ្ឋសភា លេខ 60/2014/QH13 ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦។ មាត្រា ២៩ នៃអនុក្រឹត្យលេខ 123/2015/NĐ-CP របស់រដ្ឋាភិបាល ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦។ មាត្រា ៧ នៃសារាចរណែនាំលេខ 04/2020/TT-BTP របស់ក្រសួងយុត្តិធម៌ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០។ ព្រមទាំងផ្អែកលើមាត្រា ៤ នៃអនុក្រឹត្យលេខ 120/2025/NĐ-CP របស់រដ្ឋាភិបាល ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៥ ដល់ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២៧ នោះនីតិវិធីចុះបញ្ជីកំណើតដែលមានធាតុបរទេសនៅវៀតណាមបច្ចុប្បន្ន ត្រូវអនុវត្តដូចខាងក្រោម៖

១. សមត្ថកិច្ចចុះបញ្ជីកំណើតដែលមានធាតុបរទេស៖

• ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៥ គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់ ទទួល និងដោះស្រាយការចុះបញ្ជីកំណើតជូនកុមារដែលកើតនៅវៀតណាម ដែលមានឪពុក ឬម្តាយជាពលរដ្ឋបរទេស ឬជាអ្នកគ្មានសញ្ជាតិ។ កុមារដែលកើតនៅបរទេស ត្រឡប់មករស់នៅវៀតណាម ត្រូវការចុះបញ្ជីកំណើត (តាមមាត្រា ៤ ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ 120/2025/NĐ-CP របស់រដ្ឋាភិបាល)។

• ភារកិច្ចទាក់ទងនឹងការចុះបញ្ជីកំណើត ដែលពីមុនប្រគល់ឲ្យគណៈកម្មាធិការប្រជាជនថ្នាក់ស្រុក/ការិយាល័យយុត្តិធម៌ថ្នាក់ស្រុក ត្រូវបានផ្ទេរជូនគណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់ ស្របគ្នា (ឃុំ សង្កាត់ តំបន់ពិសេស)។

២. ករណីនៃការចុះបញ្ជីកំណើតដែលមានធាតុបរទេស៖

• កុមារដែលកើតនៅវៀតណាម៖

- មានឪពុក/ម្តាយជាពលរដ្ឋវៀតណាម ឯម្នាក់ទៀតជាជនបរទេស ឬអ្នកគ្មានសញ្ជាតិ។
- មានឪពុក/ម្តាយជាពលរដ្ឋវៀតណាមរស់នៅក្នុងប្រទេស ឯម្នាក់ទៀតជាពលរដ្ឋវៀតណាមតាំងទីលំនៅនៅបរទេស។
- ទាំងឪពុក និងម្តាយ ជាជនបរទេស ឬអ្នកគ្មានសញ្ជាតិ...
- • កុមារដែលកើតនៅបរទេស មិនទាន់បានចុះបញ្ជីកំណើត ត្រឡប់មករស់នៅវៀតណាម ហើយមានឪពុកម្តាយជាពលរដ្ឋវៀតណាម (ទាំងពីរនាក់ ឬតែម្ខាង)។

៣. សំណុំឯកសារចុះបញ្ជីកំណើតដែលមានធាតុបរទេស៖

• សន្លឹកប្រកាសចុះបញ្ជីកំណើត (តាមទម្រង់)។

• លិខិតបញ្ជាក់កំណើត ឬលិខិតស្នាមផ្សេងទៀត ដែលបញ្ជាក់ថាកុមារកើតនៅបរទេស និងទំនាក់ទំនងម្តាយ-កូន (បើមាន)។

• លិខិតឆ្លងដែន ឬលិខិតស្នាមមានតម្លៃជំនួសរបស់ឪពុកម្តាយ (សម្រាប់ជនបរទេស ឬអ្នកគ្មានសញ្ជាតិ)។

• លិខិតព្រមព្រៀងរបស់ភាគី អំពីការជ្រើសរើសសញ្ជាតិជូនកូន (បើឪពុក/ម្តាយមានសញ្ជាតិផ្សេង)។

• លិខិតស្នាមបញ្ជាក់ថាកុមារចូលប្រទេសស្របច្បាប់ និងរស់នៅវៀតណាម (ក្នុងករណីកុមារកើតនៅបរទេស ត្រឡប់មករស់នៅវៀតណាម)។

• លិខិតស្នាមបញ្ជាក់អត្តសញ្ញាណរបស់អ្នកទៅចុះបញ្ជីកំណើត។

លិខិតស្នាមដែលត្រូវដាក់ស្នើ

(អនុក្រឹត្យលេខ 06/2012/NĐ-CP ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១២ របស់រដ្ឋាភិបាល)

• លិខិតបញ្ជាក់កំណើត។ ក្នុងករណីគ្មានលិខិតបញ្ជាក់កំណើត ត្រូវជំនួសដោយ៖ លិខិតរបស់សាក្សីបញ្ជាក់អំពីការសម្រាលកូន បើគ្មានលិខិតរបស់សាក្សី ត្រូវជំនួសដោយលិខិតធានាអំពីការសម្រាលកូន។ ក្នុងករណីកុមារកើតនៅបរទេស ត្រូវដាក់ស្នើលិខិតបញ្ជាក់កំណើត ឬលិខិតស្នាមផ្សេងទៀត ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចបរទេសបញ្ជាក់អំពីការដែលកុមារកើតនៅបរទេស និងទំនាក់ទំនងម្តាយ-កូន។ ក្នុងករណីអ្នកស្នើសុំបានដាក់ស្នើច្បាប់អេឡិចត្រូនិកនៃលិខិតបញ្ជាក់កំណើត ឬស្ថាប័នចុះបញ្ជីអត្រានុកូលដ្ឋានបានទាញយកទិន្នន័យអេឡិចត្រូនិកដែលមានហត្ថលេខាឌីជីថលនៃលិខិតបញ្ជាក់កំណើតរួចហើយ នោះមិនចាំបាច់ដាក់ស្នើច្បាប់ជាក្រដាសឡើយ។

• ក្នុងករណីឪពុក ឬម្តាយ ឬទាំងឪពុកម្តាយ ជាជនបរទេស ត្រូវដាក់ស្នើលិខិតព្រមព្រៀងរបស់ឪពុកម្តាយ អំពីការជ្រើសរើសសញ្ជាតិជូនកូន។ ក្នុងករណីឪពុកម្តាយជ្រើសរើសសញ្ជាតិបរទេសជូនកូន នោះក្រៅពីលិខិតព្រមព្រៀងជ្រើសរើសសញ្ជាតិ ត្រូវមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសដែលកុមារត្រូវបានជ្រើសរើសកាន់សញ្ជាតិអំពីការដែលកុមារមានសញ្ជាតិនោះ គឺស្របតាមបទប្បញ្ញត្តិច្បាប់របស់ប្រទេសនោះ។

• លិខិតប្រគល់សិទ្ធិ (ដែលបានផ្ទៀងផ្ទាត់) ស្របតាមបទប្បញ្ញត្តិច្បាប់ក្នុងករណីប្រគល់សិទ្ធិឲ្យអនុវត្តការចុះបញ្ជីកំណើត។ ក្នុងករណីអ្នកទៅចុះបញ្ជីកំណើតជូនកុមារ ជាជីដូន ជីតា ឬសាច់ញាតិដទៃទៀត នោះមិនចាំបាច់មានលិខិតប្រគល់សិទ្ធិពីឪពុកម្តាយកុមារឡើយ ប៉ុន្តែត្រូវឯកភាពជាមួយឪពុកម្តាយកុមារ អំពីខ្លឹមសារនៃការចុះបញ្ជីកំណើត។

ស្ថាប័នអនុវត្ត៖

កម្មាធិការប្រជាជន ថ្នាក់ឃុំ/សង្កាត់

១. ដោយផ្ទាល់៖

អ្នកស្នើសុំចុះបញ្ជីកំណើត អនុវត្តការដាក់ស្នើសំណុំឯកសារដោយផ្ទាល់នៅផ្នែកច្រកតែមួយ របស់គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់។

២. អនឡាញ៖

អ្នកស្នើសុំចុះបញ្ជីកំណើត ដាក់ស្នើសំណុំឯកសារតាមអនឡាញនៅលើគេហទំព័រសេវាសាធារណៈជាតិ (https://dichvucong.gov.vn)។